# សិទ្ធិ និង ការទទួលខុសត្រូវ



# របស់អ្នកមូលដ្ឋាន

**លេខាធិការនៃ HUD**

*កូនសៀវភៅឃោសនានេះមិនពាក់ព័ន្ធចំពោះកម្មវិធីទីលំនៅសាធារណៈ (Public Housing Program) ឬកម្មវិធីស្តារលទ្ធភាពជាមធ្យម ផ្នែកទី 8 (Section 8 Moderate Rehabilitation Program) ទេ (លើកលែងតែគេហដ្ឋានជាលំនៅពហុគ្រួសារ ដែល HUD បានធានា រ៉ាប់រង) និងកម្មវិធីសំបុត្របញ្ជាក់អះអាងជម្រើសទីលំនៅ (Housing Choice Voucher Program) (លើកលែងតែនៅពេលសំបុត្រ បញ្ជាក់អះអាង បានប្រើក្នុងគេហដ្ឋានជាលំនៅពហុគ្រួសារ ដែល HUD បានធានារ៉ាប់រងប្រាក់បុលទិញផ្ទះ) ។*

**រូបអ្នក ឋានៈជាអ្នកមូលដ្ឋាន (អ្នកជួលផ្ទះ) មានសិទ្ធិ និងមានការទទួលខុសត្រូវ ដែលជួយធ្វើឲ្យទីលំនៅដែល HUD ជួយ ឲ្យទៅជាផ្ទះដ៏ល្អប្រសើរ សំរាប់អ្នក និងគ្រួសាររបស់អ្នក ។**

កូនសៀវភៅឃោសនានេះ ត្រូវបានចែកចាយឲ្យអ្នក ពីព្រោះក្រសួងវឌ្ឍនកម្មទីក្រុង និងទីលំនៅ (Department of Housing and Urban Development – HUD) សហរដ្ឋ ដែលមានយុត្តាធិការផ្តាច់មុខ ទៅលើគេហដ្ឋានដែលអ្នករស់នៅ បានផ្តល់ជំនួយប្រភេទខ្លះ ឬការឧបត្ថម្ភប្រាក់ សំរាប់អាគារផ្ទះល្វែងនេះ ។  ជាផ្នែកនៃការប្តូរផ្តាច់របស់ខ្លួន ដើម្បីរក្សាបរិស្ថានការរស់នៅ ឲ្យបានល្អជាទីបំផុត សំរាប់អ្នកមូលដ្ឋានទាំងអស់ បានជាការិយាល័យ HUD នៅក្នុងតំបន់របស់អ្នក ជំរុញទឹកចិត្ត និងគាំទ្រចំពោះការនៅខាងក្រោម :

- ភ្នាក់ងារចាត់ចែងការ និងម្ចាស់ភូមិគ្រឹះ ប្រាស្រ័យទាក់ទងជាមួយអ្នកមូលដ្ឋាន ទៅលើរឿងរ៉ាវអ្វីមួយ និងគ្រប់យ៉ាងទាំងអស់ ។
- ម្ចាស់ផ្ទះ និងអ្នកចាត់ចែងការ ផ្តល់ការពិចារណាយ៉ាងរួសរាន់ ចំពោះការត្អូញត្អែរពិតប្រាកដទាំងអស់នៃអ្នកមូលដ្ឋាន និងដោះស្រាយរឿងរ៉ាវនោះយ៉ាងឆាប់រហ័ស តាមលទ្ធភាពអាចធ្វើបាន ។
- សិទ្ធិរបស់អ្នកមូលដ្ឋាន ដើម្បីរៀបចំ និងចូលរួមក្នុងការសំរេច ស្តីពីសុខុមាលភាពនៃគេហដ្ឋាន និងផ្ទះរបស់គេ ។

ដោយរួមជាមួយម្ចាស់ផ្ទះរបស់អ្នក/ភ្នាក់ងារចាត់ចែងការ អ្នកមានតួនាទីដ៏សំខាន់ ក្នុងការធ្វើឲ្យកន្លែងនៃលំនៅដ្ឋាន—គឺឬហាគឺផ្ទះឬបន្ទប់ (ផ្ទះល្វែង) ដីធ្លី និងកន្លែងទូទៅផ្សេងៗទៀត—ជាកន្លែងដ៏ល្អប្រពៃសំរាប់រស់នៅ និងក្នុងការបង្កបង្កើតសហគមន៍មួយដែលអ្នកអាចមានមោទនភាព ។

កូនសៀវភៅឃោសនានេះរៀបរាប់ត្រួសៗ អំពីសិទ្ធិ និងការទទួលខុសត្រូវខ្លះៗ ដ៏សំខាន់បំផុត ដើម្បីជួយអ្នកឲ្យទទួលបានច្រើនបំផុត ពីផ្ទះរបស់អ្នក ។



# សិទ្ធិ របស់អ្នក

ឋានៈជាអ្នកមូលដ្ឋាន នៃគេហដ្ឋានជាលំនៅពហុគ្រួសារដែល HUD ជួយ អ្នកគួរតែបានជ្រាបអំពីសិទ្ធិរបស់អ្នក ។

សិទ្ធិ

## ការជាប់ទាក់ទង ចំពោះផ្ទះល្វែងរបស់អ្នក

- មានសិទ្ធិដើម្បីរស់នៅ ក្នុងលំនៅដោយសមគួរ ដោយសុខ និងដោយមានអនាម័យ ដែលរួចចាកពីបរិស្ថានដែលគ្រោះថ្នាក់ ដូចជាថ្នាំលាបមាន-ធាតុសំណគ្រោះថ្នាក់ ។
- មានសិទ្ធិឲ្យបានទទួលការជួសជុល ក្នុងលក្ខណៈទាន់ពេលវេលា ទៅតាមសំណូមពរ និងដើម្បីឲ្យមានកម្មវិធីរក្សាគុណភាព បានគ្រប់គ្រងដោយអ្នកចាត់ចែងការ ។
- មានសិទ្ធិដើម្បីទទួលលិខិតជាលាយលក្ខណ៍អក្សរ ដោយសមហេតុផល នៃការត្រួតពិនិត្យមិនមែនជាអាសន្ន ឬការចូលទៅផ្ទះល្វែងរបស់អ្នក ។

សិទ្ធិ

## ការជាប់ទាក់ទង អង្គការអ្នកមូលដ្ឋាន

- មានសិទ្ធិដើម្បីរៀបចំ ជាអង្គការអ្នកមូលដ្ឋាន ដោយគ្មានការរាំងរា ការយាយី ឬការសងសឹក ពីសំណាក់ម្ចាស់ភូមិគ្រឹះ ឬអ្នកចាត់ចែងការ ។
- មានសិទ្ធិដើម្បីបិទសំភារៈប្រកាស នៅក្នុងកន្លែងទូទៅ និងផ្តល់ខិត្តប័ណ្ណ ជំរាបអ្នកមូលដ្ឋានផ្សេងៗទៀត អំពីសិទ្ធិ និង ឱកាសរបស់គេ ដើម្បីចូលប្រឡូកក្នុងផែនការរបស់គេ ។
- មានសិទ្ធិ ដែលអាចជាកម្មវិត្តដោយសមហេតុផល នូវថ្លៃឈ្នួលដែល HUD បានយល់ព្រម ដើម្បីប្រើកន្លែងទូទៅយ៉ាងសមរម្យ ឬកន្លែងប្រជុំ ដើម្បីរៀបចំ ឬពិចារណារឿងរ៉ាវអ្វីមួយ ដែលប៉ះពាល់ដល់លក្ខណៈ ឬការចាត់ចែងភូមិគ្រឹះ ។
- មានសិទ្ធិដើម្បីជួបជុំគ្នា ដោយគ្មានវត្តមាននៃម្ចាស់ផ្ទះ/អ្នកចាត់ចែងការ ។
- មានសិទ្ធិដើម្បីឲ្យបានទទួលស្គាល់ដោយម្ចាស់ភូមិគ្រឹះ និងអ្នកចាត់ចែងការ ជាការបញ្ចេញសំឡេងក្នុងកិច្ចការសហគន៍អ្នកមូលដ្ឋាន ។

សិទ្ធិ

## ការជាប់ទាក់ទង ការមិនរើសអើង

មានសិទ្ធិដើម្បីទទួលការប្រព្រឹត្តិមកលើ ដោយស្មើភាព និងយុត្តិធម៌ និងប្រើសេវា និងទីកន្លែងនៃអាគាររបស់អ្នក ដោយមិនប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ សាសនា ភេទ ភាពពិការ លក្ខណៈគ្រួសារ (ក្មេងៗក្រោមអាយុ 18 ឆ្នាំ) ដើមកំណើត (ជាតិពន្ធ ឬភាសា) ឬក្នុងកាលៈទេសៈខ្លះ មិនប្រកាន់អាយុ ឡើយ ។

# ការទទួលខុសត្រូវ របស់អ្នក

ឋានៈជាអ្នកមូលដ្ឋាន នៃគេហដ្ឋានជាលំនៅពហុគ្រួសារដែល HUD ជួយ អ្នកក៏មានការទទួលខុសត្រូវជាក់លាក់ ដើម្បីធ្វើឲ្យប្រាកដថា អាគាររបស់អ្នកនៅតែអាចរស់នៅដោយគួរសម សំរាប់រូបអ្នក និងអ្នកជិតខាងរបស់អ្នក ។ តាមរយៈការចុះហត្ថលេខាកិច្ចសន្យាជួលរបស់អ្នក នោះរូបអ្នក និងម្ចាស់ផ្ទះ/ក្រុមហ៊ុនចាត់ចែងការ បានព្រមព្រៀងទៅជាកុងត្រាពេញច្បាប់ ដែលអាចបង្ខំឲ្យអនុវត្ត ។ រូបអ្នក និងម្ចាស់ផ្ទះ/ក្រុមហ៊ុនចាត់ចែងការ គឺទទួលខុសត្រូវសំរាប់ការប្រតិបត្តិតាមកិច្ចសន្យាជួលរបស់អ្នក គោរពច្បាប់ទីលំនៅ និងច្បាប់ក្នុងតំបន់ដែលគ្រប់គ្រងភូមិគ្រឹះរបស់អ្នក ។ បើសិនជាអ្នកមានសំណួរអ្វី ស្តីអំពីកិច្ចសន្យាជួលរបស់អ្នក ឬបើសិនជាពុំមានសំណៅនៃកុងត្រាទេ សូមទាក់ទងភ្នាក់ងារចាត់ចែងការ ឬការិយាល័យ HUD ក្នុងតំបន់របស់អ្នក ។

## ការទទួលខុសត្រូវ

### ចំពោះម្ចាស់ភូមិគ្រឹះរបស់អ្នក ឬភ្នាក់ងារចាត់ចែងការ

- ការប្រតិបត្តិតាមច្បាប់ និងគោលការណ៍ណែនាំ ដែលគ្រប់គ្រងកិច្ចសន្យាជួលរបស់អ្នក ។
- ការបង់ប្រាក់ថ្លៃជួលត្រឹមត្រូវតាមចំនួន ដោយទាន់ពេលវេលា ទៀងទាត់រៀងរាល់ខែ ។
- ការផ្តល់ព័ត៌មានដោយត្រឹមត្រូវ ទៅឲ្យម្ចាស់ផ្ទះ នៅពេលធ្វើសំភាសន៍ការបញ្ជាក់ ឬការបញ្ជាក់សាថ្មី ដើម្បីអនុម័តថ្លៃជួលផ្ទះរបស់អ្នកសរុបទាំងអស់ និងការយល់ព្រមឲ្យបញ្ចេញព័ត៌មាន ដោយភាគីទីបី ដើម្បីអនុញ្ញាតសំរាប់ការបញ្ជាក់ ។
- ដើម្បីរាយការណ៍ពីការផ្លាស់ប្តូរ នៃប្រាក់ចំណូលគ្រួសាររបស់អ្នក ។

## ការទទួលខុសត្រូវ

### ចំពោះគេហដ្ឋាន និងអ្នកមូលដ្ឋានរស់នៅជិតខាងអ្នក

- ការប្រព្រឹត្តិខ្លួនរបស់អ្នក ក្នុងលក្ខណៈដែលនឹងមិនរំខានដល់អ្នកជិតខាងរបស់អ្នក ។
- ការមិនប្រព្រឹត្តសកម្មភាពបទឧក្រិដ្ឋនៅក្នុងគ្រឹហា ក្នុងកន្លែងទូទៅ ឬនៅលើបរិវេណ ។
- ការរក្សាគ្រឹហារបស់អ្នកឲ្យបានស្អាតបាត និងដោយមិនចោលសំរាមនៅលើបរិវេណ ឬកន្លែងទូទៅ ។
- ការចោលសំរាម និងកាកសំណល់ ក្នុងលក្ខណៈដោយត្រឹមត្រូវ ។
- ការប្រតិបត្តិតាមច្បាប់ក្នុងតំបន់ ដែលប៉ះពាល់ដល់សុខភាព ឬសុវត្ថិភាពនៃអ្នកមូលដ្ឋានទាំងពួង ។
- ការរក្សាផ្ទះល្វែងរបស់អ្នក និងកន្លែងទូទៅ ឲ្យមានលក្ខណៈល្អជាធម្មតា ដូចនៅពេលអ្នកបានរើចូលមកនៅ ។
- ការរាយការណ៍ នូវបរិស្ថានចំឡែកដែលគ្រោះថ្នាក់ ទៅអ្នកចាត់ចែងការ ដូចជាឃើញការរបកថ្នាំលាប—ដែលគ្រោះថ្នាក់ បើវាជាថ្នាំលាបមាន-ធាតុសំណ—និងការខូចអ្វីមួយនៅក្នុងប្រព័ន្ធអាគារ ការដាច់អំពូលភ្លើង ការខូចគ្រឿងប្រើអគ្គិសនី ឬផ្នែកផ្សេងៗទៀតនៃគ្រឹហា នៃបរិវេណ ឬកន្លែងដទៃទៀតដែលជាប់ទាក់ទង ។

# ការចូលរួម របស់អ្នក គឺជាសារៈសំខាន់

អ្នកមូលដ្ឋាននៅក្នុងទីលំនៅពហុគ្រួសារដែល HUD ជួយ អាចមានតួនាទីដ៏សំខាន់ ក្នុងការសំរេចអ្វីមួយដែលប៉ះពាល់ដល់គេហដ្ឋានរបស់គេ ។ កម្មវិធីរបស់ HUD ខុសៗគ្នា ផ្តល់សិទ្ធិជាក់លាក់សំរាប់អ្នកមូលដ្ឋាន ។ អ្នកមានសិទ្ធិដើម្បីដឹង ថានៅក្រោមកម្មវិធី HUD ណាមួយដែលអាគាររបស់អ្នកបានទទួលជំនួយ ។ ដើម្បីឲ្យបានដឹងថាតើអាគារផ្ទះល្វែងរបស់អ្នកបានរ៉ាប់រង នៅក្រោមលក្ខណៈណាមួយខាងក្រោម សូមទាក់ទងភ្នាក់ងារចាត់ចែងការរបស់អ្នក ។

បើអាគាររបស់អ្នកបានផ្តល់ថវិកាក្រោម**ផ្នែកទី 236, 221 (d)(3)/BMIR**, **កម្មវិធីបន្ថែមថ្លៃជួលផ្នែកទី 202 កម្មវិធីខ្ចីប្រាក់ផ្ទាល់, ផ្នែកទី 202/811 កម្មវិធីមូលធនជឿនលឿន (Rent Supplement Program, Section 202 Direct Loan Program, Section 202/811 Capital Advance Programs), ឬ បានជួយក្រោមគេហដ្ឋានយោងលើកម្មវិធី ផ្នែកទី 8 ជាធរមានណាមួយ,** និងត្រូវការនូវការយល់ព្រមជាមុនពី HUD មុននឹងម្ចាស់ផ្ទះអាចបង់ប្រាក់ជាមុន អ្នកមានសិទ្ធិចូលរួមក្នុង ឬឲ្យបានជំរាបអំពី និងផ្តល់យោបល់អំពីបញ្ហានៅខាងក្រោម ៖

- ការដំឡើងថ្លៃជួលជាអតិបរិមា ដែលអាចអនុញ្ញាតឲ្យ ។
- ការបំផ្លាស់គេហដ្ឋានមួយ ពីគេហដ្ឋានបានបង់ថ្លៃទឹកភ្លើង ទៅជាអ្នកជួលផ្ទះបង់ថ្លៃទឹកភ្លើង ឬការកាត់បន្ថយក្នុងការអនុគ្រោះថ្លៃទឹកភ្លើងរបស់អ្នកជួលផ្ទះ ។
- ការបំផ្លាស់គ្រឹហាអ្នកមូលដ្ឋាន នៅក្នុងទីលំនៅពហុគ្រួសារ ទៅជាកន្លែងមិនប្រើសំរាប់ជាលំនៅដ្ឋាន ឬទៅជាផ្ទះជួរជាប់ៗគ្នា (ផ្ទះកុនដូ) ឬផ្លាស់ទៅជាគេហដ្ឋានសាជីវកម្មជួយចេញថ្លៃអ្នកបុលប្រាក់ទិញផ្ទះ ឬជាសមាគម ។
- ការឲ្យរួចខ្លួនពីប្រាក់សន្តិសុខបុលទិញផ្ទះខ្លះ ។
- ការកែលំអមូលធន ដែលតំណាងឲ្យការបន្ថែមខ្លាំងក្លាទៅលើគេហដ្ឋាន ។
- កុងត្រាគេហដ្ឋានយោងលើផ្នែកទី ៨ មិនធ្វើជាសាថ្មីទៀត ។
- អំពីអ្វីៗផ្សេងទៀត ដែលនៅទីបញ្ចប់អាចនឹងឲ្យមានការផ្លាស់ទីលំនៅនៃអ្នកមូលដ្ឋាន ជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ដោយឥតស្ម័គ្រចិត្ត ។
- ការបង់ប្រាក់ជាមុន នៃប្រាក់បុលទិញផ្ទះ ។



# ការចូលរួម របស់អ្នក បន្ត...

បើសិនជាគ្រឹហារបស់អ្នកជាគេហដ្ឋានយោងលើកុងត្រាផ្នែកទី 8 ដែលកំពុងតែផុតអាណត្តិ ឬត្រូវបានបញ្ចប់ និងមិនបាន ធ្វើជាថ្មីទៀតទេ គ្រួសារដែលបានជួយអាចជ្រើសរើសនៅក្នុងគេហដ្ឋាននោះជាដដែលទៀត ដែលគ្រួសារកំពុងតែរស់នៅ នៅថ្ងៃខែឆ្នាំមានសិទ្ធិទទួលគេហដ្ឋាន ។ គ្រួសារ ដែលរស់នៅក្នុងគ្រឹហាដែលបានជួយ អាចនឹងមានសិទ្ធិទទួលសំបុត្របញ្ជាក់អះអាងបន្ត ។ ម្ចាស់ផ្ទះត្រូវតែផ្តល់លិខិតជំរាបដំណឹង 1 ឆ្នាំ អំពីគោលបំណងរបស់គេ ដើម្បីជ្រើសរើសចេញពីកុងត្រាផ្នែកទី 8 ។ អ្នកមូលដ្ឋានអាចប្រើសំបុត្របញ្ជាក់អះអាងផ្នែកទី 8 (Section 8 voucher) ក្នុងអាគារណាមួយដែលមានកំរិតថ្លៃជួលអាចអនុញ្ញាតបាន ។ អ្នកជួលផ្ទះដែលមានសិទ្ធិទទួល អាចទទួលសំបុត្របញ្ជាក់អះអាងបន្ត លុះត្រាតែបើគេរស់នៅក្នុងគេហដ្ឋានជាដដែលនោះទៀត ដែលគេបានរស់នៅ នៅថ្ងៃខែឆ្នាំដែលកុងត្រាផ្នែកទី 8 បានបញ្ចប់ ។ បើអ្នកជួលផ្ទះដែលមានសិទ្ធិទទួល សំរេចចិត្តរើចេញ គេមានសិទ្ធិទទួលសំបុត្របញ្ជាក់អះអាងផ្នែកទី 8 ដែល<u>មិន</u>បន្ត ។ អ្នកក៏មានសិទ្ធិ ចំពោះការប្រឹក្សានៃការផ្លាស់ទីកន្លែង (Relocation Counseling) ដែលអ្នកអាចស្វែងយល់ថែមទៀត អំពីការជ្រើសរើសទីលំនៅ ដែលមានសំរាប់អ្នក ។

> **អ្នកមូលដ្ឋានដែល HUD ជួយ គឺជាដៃគូរបស់យើង និងជាដៃគូនៅក្នុងសហគមន៍របស់គេ ។ បញ្ញត្តិ HUD ផ្តល់សិទ្ធិឲ្យអ្នកមូលដ្ឋាន ដើម្បីទាមទារឲ្យមានលក្ខណៈល្អប្រសើរ តាមរយៈការរៀបចំសមាគមអ្នកមូលដ្ឋានឯករាជ្យ ។ សមាគមន៍ទាំងនេះ ជំរុញទឹកចិត្តអ្នកមូលដ្ឋានឲ្យបានចូលប្រឡូក ក្នុងការសំរេចផ្សេងៗទៀត ដែលប៉ះពាល់ដល់ផ្ទះរបស់គេ ដោយគ្មានការយាយី ឬការសងសឹក ពីសំណាក់ម្ចាស់ភូមិគ្រឹះ ឬអ្នកចាត់ចែងការ ឡើយ ។**
>
> *—លេខាធិការនៃ HUD*

បើសិនជាអ្នករស់នៅក្នុងអាគារដែល **HUD ជាម្ចាស់** ហើយអាគារនោះត្រូវបានលក់ អ្នកមានសិទ្ធិឲ្យបានជំរាបអំពី និងបញ្ចេញយោបល់អំពីគំរោងការរបស់ HUD នៃការលក់អាគារ ។

# ជំនួយ បន្ថែម



បើសិនជាអ្នកត្រូវការព័ត៌មានថែមទៀត អ្នកអាចទាក់ទង :

- អ្នកចាត់ចែងភូមិគ្រឹះរបស់អ្នក ឬក្រុមហ៊ុនចាត់ចែងការ ។
- អ្នកចាត់ចែងគេហដ្ឋានពហុគ្រួសាររបស់ HUD, ការិយាល័យលំនៅពហុគ្រួសារ ក្នុងតំបន់ (HUD's Multifamily Hub, Multifamily Field Office), ឬអ្នកគ្រប់គ្រងកុងត្រា នៅក្នុងតំបន់របស់អ្នក ។
- ការិយាល័យ HUD ក្នុងតំបន់របស់អ្នក - http://www.hud.gov/local/index.cfm ។
- ភ្នាក់ងារការប្រឹក្សាខាងទីលំនៅ ក្នុងសហគមន៍របស់អ្នក (ទូរស័ព្ទទៅកន្លែងរកសេវាការប្រឹក្សាខាងទីលំនៅរបស់ HUD (HUD Housing Counseling Service Locator ) តាមលេខ 1–800–569–4287 សំរាប់ ជំនួយ) ។
- មជ្ឈដ្ឋានប្រមូលព័ត៌មានជាតិ នៃទីលំនៅពហុគ្រួសាររបស់ HUD (HUD's National Multifamily Housing Clearinghouse) តាមលេខ 1-800-685-8470 ដើម្បីរាយការណ៍ពីការថែរក្សា ឬបញ្ហាការចាត់ចែង ។
- លេខពិសេសនៃការិយាល័យការត្រួតពិនិត្យទូទៅរបស់ HUD (HUD's Office of Inspector General Hot Line) តាមលេខ 1-800-347-3735 ដើម្បីរាយការណ៍អំពីការគៃបន្លំ អំពីសំរាម ឬការចាត់ចែងមិនត្រឹមត្រូវ ។
- ដីកាកោះ ចំពោះច្បាប់ទីលំនៅពហុគ្រួសារ (Multifamily Housing Rule) —24 CFR ភាគ 245 ។
- បណ្តាញអ៊ិនទ័រណិតទូទាំងសាកលលោក - http://www.hud.gov

បើសិនជាអ្នកជឿថា គេបានរើសអើងប្រឆាំងនឹងអ្នក ឬបើចង់ទទួលព័ត៌មានស្តីពីលក្ខន្តិកៈអ្វីខ្លះ នៃការរើសអើងទីលំ នៅ សូមទូរស័ព្ទទៅលេខ 1–800–669– 9777 ឬទូរស័ព្ទទៅការិយាល័យនៃទីលំនៅសមរម្យ និងឱកាសស្មើភាព HUD (HUD Office of Fair Housing and Equal Opportunity) ។

ការិយាល័យរដ្ឋាភិបាលក្នុងតំបន់របស់អ្នក ផ្នែកខាងកិច្ចការអ្នកជួលផ្ទះ/ម្ចាស់ផ្ទះ ឬការិយាល័យសេវាខាងច្បាប់ និង អង្គការអ្នកជួលផ្ទះ ក៏អាចផ្តល់ព័ត៌មានជូនអ្នក ស្តីពីសិទ្ធិរបស់អ្នកថែមទៀត នៅក្រោមច្បាប់រដ្ឋាភិបាលក្នុងតំបន់ ឬ រដ្ឋ ផងដែរ ។

កូនសៀវភៅឃោសនា ស្តីអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នក ឋានៈជាអ្នកមូលដ្ឋាននៃពហុគ្រួសារដែល HUD ជួយ គឺមានជាភាសាផ្សេងៗទៀត ក្រៅពីអង់គ្លេស ។ ដើម្បីសាកសួរថាតើភាសាណាមួយ ដែលមាននៅ ពេលបច្ចុប្បន្ននេះ សូមទាក់ទងមជ្ឈដ្ឋានប្រមូលព័ត៌មានជាតិ នៃទីលំនៅពហុគ្រួសាររបស់ HUD តាមលេខ 1–800–685–8470 ។

**U.S. Department of Housing and Urban Development**
*Office of Multifamily Housing Programs*

Washington, DC 20410-0000
Official Business
Penalty for Private Use $300